## តើធ្វើដូចម្តេចដើម្បីទទួលបានហិរញ្ញប្បទានឥតសំណង បំពេញបន្ថែមទុនវិនិយោគ?

១ ចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយ

២ ស្វែងរកដៃគូអាជីវកម្ម

៣ រៀបចំផែនការពិពិធកម្ម និងផែនការធុរកិច្ច

៤ ដាក់ផែនការពិពិធកម្ម និងផែនការធុរកិច្ច ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៥ វាយតម្លៃ អនុម័ត ផែនការពិពិធកម្ម និង ផែនការធុរកិច្ច និងចុះកិច្ចព្រមព្រៀង

### ទំនាក់ទំនង៖


+855-077-563-377 |012-642-767

chetrass@gmail.com OR sophoeun_nop@yahoo.com

www.casdp.maff.gov.kh

អគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ


CASDP



# ការទទួលសំណើសុំជំនួយហិរញ្ញប្បទាន ឥតសំណងបំពេញបន្ថែមទុនវិនិយោគ

**Matching Grant Facility (MGF)**


អនុវត្តដោយ៖

គាំទ្រដោយ៖ THE WORLD BANK IBRD • IDA | WORLD BANK GROUP



## គម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP)

គម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) បង្កើតឡើងក្នុងគោលបំណង
គម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) បង្កើតឡើងក្នុងគោលបំណង
សម្របសម្រួលខ្សែច្រវាក់តម្លៃពិពិធកម្មកសិកម្មនៅក្នុងតំបន់ភូមិសាស្ត្រនៃខេត្តគោលដៅរបស់គម្រោងក្នុងប្រទេសកម្ពុជា និងផ្តល់អន្តរាគមន៍ឆ្លើយតបបន្ទាន់ប្រកបដោយប្រសិទ្ធភាពក្នុងករណីមានវិបត្តិ។

គម្រោងបាននឹងកំពុងអនុវត្តក្រោម ហិរញ្ញប្បទានឥណទានពីធនាគារពិភពលោក ចំនួន ៩១,៦៧ លានដុល្លារអាមេរិក និង ថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ១០លាន ដុល្លារអាមេរិក សម្រាប់អនុវត្តសកម្មភាពក្នុងខេត្តគោលដៅចំនួន ១៨ រួមមាន៖. ខេត្តបាត់ដំបង សៀមរាប ព្រះវិហារ ស្ទឹងត្រែង រតនគិរី ក្រចេះ មណ្ឌលគិរី ត្បូងឃ្មុំ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល ពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ធំ តាកែវ និងរាជធានីភ្នំពេញ។



### តើអ្វីទៅជាការទទួលបានជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (MGF)?

ការទទួលបានជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (MGF) ជាហិរញ្ញប្បទានប្រកួតប្រជែងក្រោមគម្រោង CASDP ដែលគាំទ្រសហគមន៍កសិកម្ម ក្រុមផលិត និងសមាជិកក្រុម កសិធុរកិច្ច និងអ្នកកែច្នៃកសិផលធ្វើឱ្យប្រសើរឡើងទាំងបរិមាណនិងគុណភាព ដើម្បីនាំចេញទៅកាន់ទីផ្សារ។

### តើអ្វីទៅជា “ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ”?

ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ ជា “ថវិកាជំនួយសម្រាប់បំពេញបន្ថែមចំនួន ៤០%នៃការវិនិយោគ” ផ្តល់ជូនសហគមន៍កសិកម្ម ក្រុមផលិត ដែលបានរៀបចំ “ផែនការពិពិធកម្ម និងផែនការធុរកិច្ច” និងស្នើមកគម្រោង។

### តើហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគផ្តល់ជូនសហគមន៍កសិកម្ម និងក្រុមផលិត ជាលុយសុទ្ធមែនឬទេ?

ហិរញ្ញប្បទាននេះ មិនផ្តល់ជាលុយសុទ្ធជូនសហគមន៍កសិកម្ម និង ក្រុមផលិតទេ គឺគម្រោងនឹងផ្តល់ជូនបន្ទាប់ពី សហគមន៍បានទទួលសម្ភារៈឬសេវាកម្មដែលគ្រោងទិញ ហើយទូទាត់ជូនអ្នកផ្គត់ផ្គង់រួចរាល់តាមនីតិវិធីលទ្ធកម្ម។ តាមរយៈជំនួយហិរញ្ញប្បទាននេះ ក្រុមការងារបច្ចេកទេសលទ្ធកម្ម និងហិរញ្ញវត្ថុរបស់គម្រោងនឹងជួយសហគមន៍កសិកម្ម និងក្រុមផលិតលើដំណើរការនីតិវិធីលទ្ធកម្ម និងហិរញ្ញវត្ថុ ស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងផ្តល់ជំនួយ។



## តើត្រូវមានលក្ខខណ្ឌអ្វីខ្លះ សម្រាប់សមាជិកសហគមន៍កសិកម្ម ឬ ក្រុមផលិត ដើម្បីទទួលបានជំនួយពីគម្រោង?

សហគមន៍កសិកម្ម និង ក្រុមផលិត ត្រូវមានលក្ខខណ្ឌតម្រូវសំខាន់ៗ ដូចជា៖

- មានដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួន
- មានរបាយការណ៍ប្រតិបត្តិការកសិកម្មត្រឹមត្រូវ
- មិនប្រើប្រាស់សារធាតុគីមីដែលហាមឃាត់
- អនុវត្តតាមគោលការណ៍កសិកម្មល្អ (GAP), ការអនុវត្តអនាម័យល្អ (GHP), ការអនុវត្តចិញ្ចឹមសត្វល្អ (GAHP), ការអនុវត្តល្អក្នុងរោងចក្រសហគ្រាស (GMP)
- គិតគូរដល់កិច្ចគាំពារបរិស្ថាន និងសង្គម
- ផ្តល់អាទិភាពដល់សមាជិកសហគមន៍កសិកម្ម ក្រុមផលិត ដែលមានតម្រូវការវិនិយោគ
- មានសមាជិកជាស្ត្រី ឬថ្នាក់ដឹកនាំជាស្ត្រី និង
- មានទុនបដិភាគ ៦០% ចូលរួម
- មានសក្តានុពលកសិកម្ម (ដីមានជីជាតិ មានប្រភពទឹក និងមានទីផ្សារ
- មានលក្ខខណ្ឌ និងសកម្មភាពផ្សេងទៀតជាតម្រូវការគម្រោង។



## តើឧបករណ៍បរិក្ខារកសិកម្ម ឬសេវាកម្មប្រភេទណាខ្លះដែលអាចទទួលបានជំនួយហិរញ្ញប្បទាន ៤០%?

សម្ភារបរិក្ខារកសិកម្ម គ្រឿងយន្តកសិកម្ម និង/ឬ សេវាកម្ម ដែលអាចទទួលបានហិរញ្ញប្បទានរួមមាន៖

### ✓ ការសាងសង់អាគារ



ការវិនិយោគទាក់ទងនឹងសកម្មភាពផលិតកម្មកសិកម្ម ដូចជា៖ ឃ្លាំងស្តុក កន្លែងវេចខ្ចប់ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងកសិដ្ឋាន និងការពង្រាបដី ជាដើម។

### ✓ បរិក្ខារប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋាន



បរិក្ខារស្រោចស្រព រួមមាន ម៉ាស៊ីនបូមទឹក ម៉ាស៊ីនបាញ់ទឹក ប្រព័ន្ធសូឡា ទុយោបាញ់ទឹក និងគ្រឿងប្រើប្រាស់ផ្សេងទៀត។

### ✓ បរិក្ខារកសិកម្ម



បរិក្ខារកសិកម្ម និងគ្រឿងយន្តកសិកម្មលើកកម្ពស់ផលិតកម្ម ដូចជាម៉ាស៊ីនភ្ជួរដី ត្រាក់ទ័រខ្នាតតូច សាស័រ ម៉ាស៊ីនកំដៅឡសម្ងួត និងម៉ាស៊ីនច្រូតជាដើម។

## ឧបករណ៍បរិក្ខារកសិកម្មខ្នាតតូច



ឧបករណ៍បរិក្ខារកសិកម្មខ្នាតតូច រួមមាន ចបកាប់ ប៉ែល រទេះរុញ ឧបករណ៍បាញ់ថ្នាំ ឧបករណ៍ផ្លុំខ្យល់ ឧបករណ៍កាត់ស្មៅ ប្រាសជុស ។ល។

## ឧបករណ៍ផ្ទះសំណាញ់



ផ្ទះសំណាញ់ សម្ភារៈដាំដុះលើទឹក (hydroponics) និងបច្ចេកទេសទំនើបផ្សេងទៀត។

## ឧបករណ៍ចិញ្ចឹមឃ្មុំ



ឧបករណ៍ចិញ្ចឹមឃ្មុំ មេឃ្មុំ និងគ្រឿងបរិក្ខារគាំទ្រមួយចំនួនទៀត។

## គ្រឿងបរិក្ខារក្រោយប្រមូលផល



គ្រឿងបរិក្ខារក្រោយប្រមូលផល និងកែច្នៃចំណីអាហារខ្នាតតូច ក្នុងកសិដ្ឋាន រួមមានម៉ាស៊ីនកិន ប្រដាប់អួសឬនាស់ ម៉ាស៊ីនចម្រាញ់ប្រេងឆា ។ល។

## ឧបករណ៍វេចខ្ចប់ និងស្លាកសញ្ញា



ឧបករណ៍វេចខ្ចប់ រួមជាមួយនឹងបច្ចេកវិទ្យាដែលបម្រើឱ្យការកែច្នៃដើម្បីបង្កើនគុណភាពផលិតផលសម្រេច

## សេវាពាក់ព័ន្ធការកែច្នៃបឋម



សេវាបញ្ជាក់គុណភាព និងបណ្តុះបណ្តាល

## គ្រឿងបរិក្ខារ និងម៉ាស៊ីនកែច្នៃម្ហូបអាហារ



គ្រឿងបរិក្ខារ និងម៉ាស៊ីនកែច្នៃម្ហូបអាហារ រួមមាន៖ម៉ាស៊ីនសម្ងួត ម៉ាស៊ីនកំដៅ ម៉ាស៊ីនកែច្នៃផ្លែឈើ ទូត្រជាក់ ម៉ាស៊ីនបង្កក ម៉ាស៊ីនច្រូតកាត់ និងសម្ភារៈបច្ចេកទេសបម្រើឱ្យខ្សែច្រវាក់តម្លៃផ្សេងទៀត។





ផ្តល់ហិរញ្ញប្បទានឥតសំណង ៤0%
ដល់សហគមន៍កសិកម្ម និងក្រុមផលិត



## តើហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគនេះ មានទំហំប៉ុន្មាន?

- គម្រោងផ្តល់ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ ចំនួន ៤0% នៃទុនវិនិយោគ (ឬច្រើនបំផុតត្រឹម៤00 000 ដុល្លារអាម៉េរិក)។ ក្នុងនោះដែរ សហគមន៍កសិកម្ម និងក្រុមអ្នកផលិត ត្រូវមានថវិកាបដិភាគយ៉ាងតិចណាស់ ៦0% នៃទុនវិនិយោគ។ ចំណែកឯ ទំហំទឹកប្រាក់ដែលស្នើឡើងក្នុងផែនការពិពិធកម្ម និងផែនការធុរកិច្ច សម្រាប់គម្រោង ដែលមានលក្ខណៈជាខ្សែច្រវាក់តម្លៃ ច្រើនបំផុតត្រឹម ១ 000 000 ដុល្លារ។
- គម្រោងផ្តល់ ៤0% ឬច្រើនបំផុត ១ 000 00 ដុល្លារ កម្រឹតសហគមន៍
- គម្រោងផ្តល់ ៤0% ឬច្រើនបំផុតត្រឹម ៣ 000 ដុល្លារ ក្នុង១នាក់។



## តើសហគមន៍កសិកម្ម និងក្រុមផលិត ត្រូវដាក់សំណើសុំហិរញ្ញប្បទានឥតសំណងដោយរបៀបណា នៅពេលណា និងនៅកន្លែងណា?

ក្រោយពីទទួលបានព័ត៌មានអំពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា សហគមន៍កសិកម្មដែលមានបំណងស្នើសុំជំនួយពីគម្រោង អាចទំនាក់ទំនងទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ឬទាក់ទងក្រុមការងារផ្តល់សេវាបច្ចេកទេស (TSP) ដើម្បីគាំទ្របច្ចេកទេសក្នុងការរៀបចំផែនការពិពិធកម្ម និងផែនការធុរកិច្ច រួចដាក់ជូនគម្រោងពិនិត្យ និងវាយតម្លៃ។ សហគមន៍កសិកម្មអាចដាក់ផែនការពិពិធកម្ម និងផែនការធុរកិច្ចមកគម្រោងផ្ទាល់ ឬតាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត។